**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**
**អគ្គលេខាធិការដ្ឋាន**
លេខ:៣៦/២០១៦ អ.កបធ.សជណ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមទូលថ្វាយ និងជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅថ្ងៃអង្គារ ទី២១ ខែមិថុនា ឆ្នាំ២០១៦ ចាប់ពីម៉ោង ០៩: ០០ព្រឹក នៅអគារ "ស" នៃវិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំក្រោមអធិបតីភាពសមាជិកដែលមានអាយុច្រើនជាងគេ ដែលមានវត្តមានដឹកនាំអង្គប្រជុំ ដើម្បីបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អាណត្តិ ៣ឆ្នាំ លើកទី៧ (ឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៩)។

ជាលទ្ធផលក្រុមប្រឹក្សាធម្មនុញ្ញបានបោះឆ្នោតជ្រើសតាំងឯកឧត្តម **អ៊ឹម ឈុនលឹម** ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញអាណត្តិ ៣ឆ្នាំ លើកទី៧ ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១០: ០០ព្រឹក ថ្ងៃអង្គារ ទី២១ ខែមិថុនា ឆ្នាំ២០១៦ ។

អាស្រ័យដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៦

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ